**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# គោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥

**សម្រេច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់គោលការណ៍ជាមូលដ្ឋានទាំងឡាយ សម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី ដើម្បីអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ថ្លៃលក់អគ្គិសនីឱ្យបានសមស្របចំពោះអ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិច្បាប់ ។

**មាត្រា ២.-**

អាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់សេវាអគ្គិសនីតាមថ្លៃណាមួយ ដែលមិនអាចរំលោះចំណាយត្រឹមត្រូវទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណឡើយ លើកលែងតែមានការឧបត្ថម្ភ ឬការបំពេញខាតជាក់លាក់ណាមួយផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណនោះ ។

**មាត្រា ៣.-**

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចេញបទប្បញ្ញត្តិស្តីពីគោលការណ៍លម្អិតនិងវិធីសាស្ត្រ សម្រាប់គណនានិងកំណត់បរិមាណចំណាយត្រឹមត្រូវខាងលើ ។

## ជំពូកទី ២
## វិធីសាស្ត្រសម្រាប់វាយតម្លៃការត្រឹមត្រូវនៃចំណាយ

**មាត្រា ៤.-**

ចំណាយត្រឹមត្រូវរបស់អ្នកកាន់អាជ្ញាប័ណ្ណ គឺជាចំនួនសរុបនៃចំណាយត្រឹមត្រូវតាមខ្ទង់ចំណាយ ដូចខាងក្រោម ៖

១- ចំណាយដំណើរការនិងការថែទាំ

២- ចំណាយទិញប្រេងឥន្ធនៈ

៣- ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ

៤- ចំណាយទិញអគ្គិសនី

៥- ចំណាយសម្រាប់រំលោះអចលនទ្រព្យ

៦- ប្រាក់ចំណេញនិងចំណាយប្រើប្រាស់ឥណទាន

៧- ចំណាយដទៃផ្សេងទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាសមស្រប ។

**មាត្រា ៥.-**

នៅក្នុងការពិនិត្យឡើងវិញ និងនៅក្នុងការកំណត់ថ្លៃលក់អគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវរបាយការណ៍គណនេយ្យ និងព័ត៌មានទាំងឡាយ ដែលរួមមានព័ត៌មានស្តីអំពីចំណាយតាមខ្ទង់ចំណាយនីមួយៗដូចបញ្ជាក់ក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ស្របទៅតាមទម្រង់និងឯកសារដែលមានណែនាំនៅក្នុងនីតិវិធី និងបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងព័ត៌មានដទៃផ្សេងទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការ ។

**មាត្រា ៦.-**

ការផ្ទៀងផ្ទាត់ និងការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយ ត្រូវធ្វើតាមខ្ទង់ចំណាយនីមួយៗ ដោយអនុលោមទៅតាមគោលការណ៍ជាមូលដ្ឋានទាំងឡាយដែលមានកំណត់នៅក្នុងជំពូកទី ៣ នៃអនុក្រឹត្យនេះ ព្រមទាំងគោលការណ៍លម្អិតនិងវិធីសាស្ត្រទាំងឡាយដែលកំណត់នៅក្នុងបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

**មាត្រា ៧.-**

ក្នុងការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាច ៖

- អនុវត្តវិធីសាស្ត្រខុសគ្នាចំពោះអ្នកកាន់អាជ្ញាប័ណ្ណខុសគ្នា ក្នុងករណីដែលការអនុវត្តន៍របៀបនេះជាការចាំបាច់ ដើម្បីឱ្យសមស្របតាមទំហំ ទីតាំង និងស្ថានភាពខុសៗគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណ
- ទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ព័ត៌មានចំណាយដោយឡែកតាមប្រភេទអាជីវកម្មនីមួយៗ ដើម្បីវាយតម្លៃភាពត្រឹមត្រូវនៃចំណាយសម្រាប់អាជីវកម្មដោយឡែកនីមួយៗនោះ ដែលរួមមានអាជីវកម្មផលិតកម្ម អាជីវកម្មបញ្ជូន អាជីវកម្មចែកចាយ
- ទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ព័ត៌មានចំណាយដោយឡែក តាមតំបន់សេវាកម្មនីមួយៗ ដើម្បីវាយតម្លៃភាពត្រឹមត្រូវនៃចំណាយតាមតំបន់សេវាកម្មដោយឡែកនីមួយៗនោះ
- ប្រើប្រាស់វិធីសាស្ត្រកំណត់កម្រិតចំណាយត្រឹមត្រូវលើមូលដ្ឋានប្រសិទ្ធភាពនៃការអនុវត្តន៍ ដើម្បីជំរុញឱ្យអ្នកកាន់អាជ្ញាប័ណ្ណបន្ថយចំណាយ បង្កើនប្រសិទ្ធភាព និងកែលម្អគុណភាពសេវាអគ្គិសនី ។

អាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវប្រើវិធីសាស្ត្រកំណត់កម្រិតចំណាយត្រឹមត្រូវណាមួយ ដែលប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុក្នុងរយៈពេលវែងនៃអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណឡើយ ។

## ជំពូកទី ៣

## គោលការណ៍ជាមូលដ្ឋានសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយតាមខ្នង

**មាត្រា ៨.-**

ចំពោះចំណាយដំណើរការនិងការថែទាំ ៖

១- អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណរំលោះតែចំណាយដំណើរការនិងការថែទាំណា ដែលចាំបាច់សម្រាប់ផ្តល់សេវាអគ្គិសនីតាមកម្រិតស្តង់ដាសមស្រប និងដែលបានអនុវត្តដោយប្រុងប្រយ័ត្នប៉ុណ្ណោះ ។

២- ក្នុងគ្រប់ករណី ភាពត្រឹមត្រូវនៃចំណាយដំណើរការនិងការថែទាំ ត្រូវកម្រិតត្រឹមចំនួនមួយដែលសហគ្រាសប្រកបដោយប្រសិទ្ធភាពសមស្របត្រូវការចាំបាច់ក្នុងការដំណើរការ ស្របតាមស្ថានភាពជាក់ស្តែងរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

៣- សំវិធានធនសម្រាប់បំណុលពិបាកទារត្រូវចាត់ទុកថាជាចំណាយមួយក្នុងដំណើរការ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណអាចបង្ហាញអាជ្ញាធរអគ្គិសនីកម្ពុជាថា ការប្រមូលចំណូលរបស់ខ្លួនប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ហើយកម្រិតនៃបំណុលពិបាកទារនេះគឺជាចំនួនមួយដែលមិនអាចជៀសវាងបានតាមល័ក្ខខ័ណ្ឌទីតាំងអាជីវកម្មនិងកាតព្វកិច្ចសង្គមរបស់ខ្លួន ។

**មាត្រា ៩.-**

ចំពោះចំណាយទិញប្រេងឥន្ធនៈ ៖

១- ជាទូទៅ ចំណាយទិញប្រេងឥន្ធនៈត្រូវចាត់ទុកថាជាចំណាយត្រឹមត្រូវ តែក្នុងករណីដែលចំណាយនោះបានធ្វើឡើងតាមថ្លៃទិញមួយទាបជាងគេដែលអាចទិញបាន សម្រាប់ស្ថានភាពជាក់ស្តែងរបស់អ្នកកាន់អាជ្ញាប័ណ្ណប៉ុណ្ណោះ ។

២- ចំពោះអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មតូចៗ ថ្លៃប្រេងឥន្ធនៈត្រឹមត្រូវគឺជាថ្លៃប្រេងឥន្ធនៈនៃទីផ្សារណាមួយនៃតំបន់នោះ ដែលកំណត់តាមគោលការណ៍នៃចំណុច១នៃមាត្រានេះ បូកបន្ថែមថ្លៃដឹកជញ្ជូនពីទីផ្សារនោះដល់ទីតាំងផលិតកម្ម ។

៣- ចំពោះអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនីធំៗ ទោះបីជាការទិញប្រេងឥន្ធនៈដោយខ្លួនឯងផ្ទាល់ ឬការទិញប្រេងឥន្ធនៈតាមរយៈកិច្ចព្រមព្រៀងជាមួយផលិតករអគ្គិសនីឯករាជក៏ដោយ ថ្លៃប្រេងឥន្ធនៈដែលត្រឹមត្រូវ គឺជាថ្លៃមួយដែលឆ្លុះបញ្ចាំងថ្លៃប្រេងឥន្ធនៈនៅទីផ្សារអន្តរជាតិ ដោយបូកបន្ថែមកម្រៃផ្សេងៗទៀតដូចជា ថ្លៃដឹកជញ្ជូន និងពន្ធពាក់ព័ន្ធ ហើយថ្លៃទាំងនេះត្រូវកំណត់ដោយការប្រកួតប្រជែងដេញថ្លៃត្រឹមត្រូវ ។

៤- នៅក្នុងករណីថ្លៃប្រេងឥន្ធនៈមានការប្រែប្រួលជាប្រចាំ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណរំលោះលំអៀងថ្លៃប្រេងដែលលើស តាមរយៈថ្លៃលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ដោយប្រើប្រាស់រូបមន្តកែតម្រូវថ្លៃលក់តាមថ្លៃប្រេងមួយ ដែលអនុម័តដោយអាជ្ញាធរ ។

## មាត្រា ១០.-

ចំពោះចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ ៖

១- ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅត្រូវសមស្របទៅតាមទំហំអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងត្រូវកម្រិតត្រឹមតែការងារណាដែលចាំបាច់សម្រាប់អាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណប៉ុណ្ណោះ ។

២- ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណមានអាជ្ញាប័ណ្ណរួមឬធ្វើសេវាកម្មលើតំបន់ច្រើន លើសពីមួយ អ្នកកាន់អាជ្ញាប័ណ្ណចាំបាច់ត្រូវតែបែងចែកចំណាយរួម ពាក់ព័ន្ធនឹងសហគ្រាសទាំងមូល ជាផ្នែកទៅតាមប្រភេទអាជីវកម្ម និងទៅតាមតំបន់សេវាកម្មដោយឡែកនីមួយៗ ហើយការបែងចែកចំណាយរួមទៅតាមប្រភេទអាជីវកម្មនិងតំបន់សេវាកម្មនោះ ត្រូវមានការពិនិត្យនិងឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

៣- នៅពេលណាដែលតម្រូវឱ្យមានការធានារ៉ាប់រង ចំណាយលើការធានារ៉ាប់រងត្រូវកម្រិតត្រឹមចំនួនមួយដែលចាំបាច់និងសមស្របសម្រាប់អាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើការបង្ហាញថា ការធានារ៉ាប់រងនេះគឺជាការចាំបាច់ ហើយថ្លៃចំណាយសម្រាប់ការធានារ៉ាប់រងនេះ គឺជាថ្លៃមួយទាបជាងគេដែលសមស្របអាចរកបាន នៅក្នុងស្ថានភាពជាក់ស្តែងរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

## មាត្រា ១១.-

ចំពោះចំណាយទិញអគ្គិសនី ៖

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវទិញអគ្គិសនីតាមថ្លៃនិងល័ក្ខខ័ណ្ឌមួយ ដែលមានប្រសិទ្ធភាពនិងប្រកួតប្រជែងជាងគេ ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាជាមុន លើថ្លៃនិងល័ក្ខខ័ណ្ឌនៃការទិញអគ្គិសនី ដោយអនុលោមតាមបទប្បញ្ញត្តិនិងអាជ្ញាប័ណ្ណ មុនចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញលក់អគ្គិសនីជាមួយភាគីមួយទៀត ។

២- ប្រសិនបើការទិញអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើឡើងក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនីមួយដែលបានចុះហត្ថលេខាមុនពេលច្បាប់ស្តីពីអគ្គិសនីចូលជាធរមាន អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណរំលោះថ្លៃទិញអគ្គិសនីតាមអាណត្តិនិងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនោះ ស្របតាមការកំណត់ក្នុងមាត្រា ៧៦ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

៣- នៅក្នុងគ្រប់ករណី បន្ទាប់ពីចុះកិច្ចព្រមព្រៀងទិញលក់អគ្គិសនីរួច ចំណាយលើការទិញអគ្គិសនីត្រូវចាត់ទុកថាជាចំណាយត្រឹមត្រូវ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណអាចបង្ហាញថា ៖

- បរិមាណអគ្គិសនីដែលទិញក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនីមួយៗ ត្រឹមត្រូវទៅតាមលំដាប់អាទិភាពនៃការទទួលអគ្គិសនីពីរោងចក្រអគ្គិសនីដែលមាន អនុលោមទៅតាមការអនុវត្តន៍ជាធម្មតារបស់សហគ្រាសអគ្គិសនី និង

- ថ្លៃប្រេងឥន្ធនៈដែលប្រើប្រាស់សម្រាប់គណនាថ្លៃទិញអគ្គិសនី គឺជាថ្លៃមួយសមស្របតាមថ្លៃដែលប្រសើរជាងគេនៃទីផ្សារប្រេងឥន្ធនៈ ដែលអាចរកបាននៅពេលទិញប្រេងឥន្ធនៈ ។

**មាត្រា ១២.-**

ចំពោះចំណាយសម្រាប់រំលោះអចលនទ្រព្យ ៖

១- អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការរំលោះតម្លៃដើមនៃអចលនទ្រព្យរបស់ខ្លួន តាមរយៈខ្ទង់ចំណាយសម្រាប់រំលោះអចលនទ្រព្យ ។ តម្លៃដើមនៃអចលនទ្រព្យត្រូវកំណត់តាមគោលការណ៍ក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។ តម្លៃពិតនៃអចលនទ្រព្យរបស់អ្នកកាន់អាជ្ញាប័ណ្ណនៅកាលបរិច្ឆេទណាមួយ ត្រូវជាតម្លៃដើមនៃអចលនទ្រព្យនោះដែលបានកែតម្រូវទៅតាមទឹកប្រាក់ដែលបានរំលោះជាបន្តបន្ទាប់ ។

២- វិធានលម្អិតសម្រាប់ធ្វើការកំណត់ចំណាយសម្រាប់រំលោះអចលនទ្រព្យ ត្រូវផ្អែកលើគោលការណ៍ទាំងឡាយ ដូចខាងក្រោម ៖

ក. ត្រូវប្រើប្រាស់វិធីរំលោះស្មើ សម្រាប់រំលោះអចលនទ្រព្យ ។

ខ. អាយុកាលនៃរំលោះសម្រាប់អចលនទ្រព្យណាមួយ ឬក្រុមអចលនទ្រព្យណាមួយ ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋាននៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនៃអចលនទ្រព្យនោះ និងត្រូវគោរពតាមស្តង់ដាគណនេយ្យណាមួយដែលកំពុងប្រើប្រាស់ ។

វិធានលម្អិតដើម្បីធ្វើការកំណត់ចំណាយសម្រាប់រំលោះអចលនទ្រព្យ អាចអនុញ្ញាតឱ្យងាកចេញពីគោលការណ៍នៃចំណុចទី២នៃមាត្រានេះបាន តែក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាជឿជាក់ថា គោលការណ៍ទាំងនេះធ្វើឱ្យមានការប្រែប្រួលខ្លាំងដល់បញ្ជីថ្លៃលក់អគ្គិសនី ឬធ្វើឱ្យមានការលំបាកខ្លាំងដល់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការទូទាត់ប្រាក់ដើមនៃឥណទានប៉ុណ្ណោះ ។

## មាត្រា ១៣.-

ចំពោះប្រាក់ចំណេញនិងចំណាយប្រើប្រាស់ឥណទាន ៖

១- អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណមានប្រាក់ចំណេញសមស្របលើមូលធនដាក់ស្តែងផ្ទាល់របស់ខ្លួន ។ ប្រាក់ចំណេញសមស្របដែលអនុញ្ញាតឱ្យរំលោះតាមថ្លៃលក់អគ្គិសនី ត្រូវគណនាតាមអត្រានៃប្រាក់ចំណេញដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមទៅតាមស្ថានភាព ទំហំ តំបន់ និងប្រភេទនៃអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ មូលធនដាក់ស្តែងផ្ទាល់ដែលអ្នកកាន់អាជ្ញាប័ណ្ណបានប្រើប្រាស់ក្នុងអាជីវកម្មសម្រាប់កាលបរិច្ឆេទណាមួយ គឺជាតម្លៃពិតនៃអចលនទ្រព្យរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដូចមានកំណត់ក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ បូកបន្ថែមនូវទុនចល័តដែលបានអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងដកចេញនូវឥណទានទាំងឡាយណា ដែលបានខ្ចីពីស្ថាប័នហិរញ្ញប្បទាន ។

២- ប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគិតគូរដល់សេចក្តីត្រូវការនៃការពង្រីកនិងកែលម្អអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ យ៉ាងណាដែលអាចឱ្យអ្នកកាន់អាជ្ញាប័ណ្ណមានលទ្ធភាពបំពេញបាននូវសំណូមពរដ៏សមស្របរបស់អ្នកប្រើប្រាស់ឬអាជ្ញាធរអគ្គិសនីកម្ពុជា និងត្រូវធានាតុល្យភាពមួយសមស្របរវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់និងផលប្រយោជន៍របស់អ្នកកាន់អាជ្ញាប័ណ្ណ ។

៣- ប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគិតគូរដល់ស្ថិរភាពហិរញ្ញវត្ថុនិងកាតព្វកិច្ចបង់ពន្ធទាំងឡាយរបស់អ្នកកាន់អាជ្ញាប័ណ្ណស្របតាមការកំណត់របស់ច្បាប់ លើកលែងតែ អាករលើតម្លៃបន្ថែម ប្រសិនបើមាន ។ អាករលើតម្លៃបន្ថែមមិនត្រូវបញ្ចូលទៅក្នុងចំណាយឡើយ ហើយត្រូវដាក់ឱ្យអ្នកប្រើប្រាស់ទូទាត់តាមខ្ទង់មួយដោយឡែក នៅក្នុងវិក្កយបត្រអគ្គិសនី ។

៤- បន្ថែមលើប្រាក់ចំណេញដែលបានអនុញ្ញាតទៅតាមចំនួនមូលធនដាក់ស្តែងផ្ទាល់ អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការរំលោះចំណាយប្រើប្រាស់ឥណទានដែលបានខ្ចីពីស្ថាប័នហិរញ្ញប្បទានសម្រាប់វិនិយោគលើមធ្យោបាយអាជីវកម្មរបស់ខ្លួន ។ ចំណាយប្រើប្រាស់ឥណទានគឺជាចំណាយទាំងឡាយសម្រាប់ទូទាត់ការប្រាក់ និងកម្រៃផ្សេងៗក្នុងការប្រើប្រាស់ឥណទាន ។

## មាត្រា ១៤.-

ដើម្បីធានាភាពត្រឹមត្រូវនៃចំណាយសម្រាប់រំលោះអចលនទ្រព្យ ព្រមទាំងប្រាក់ចំណេញនិងចំណាយប្រើប្រាស់ឥណទាន ដែលមានកំណត់នៅក្នុងមាត្រា ១២ និងមាត្រា ១៣ នៃអនុក្រឹត្យនេះ ចាំបាច់ត្រូវវាយ

តម្លៃទ្រព្យសកម្មនិងមូលធនផ្សេងៗ ដែលអ្នកកាន់អាជ្ញាប័ណ្ណប្រើប្រាស់ក្នុងអាជីវកម្មខ្លួនឱ្យបានត្រឹមត្រូវ ។ ការវាយតម្លៃទ្រព្យសកម្មនិងមូលធនផ្សេងៗរបស់អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

១- តម្លៃដើមនៃអចលនទ្រព្យដែលអ្នកកាន់អាជ្ញាប័ណ្ណប្រើប្រាស់ក្នុងអាជីវកម្ម ត្រូវជាថ្លៃចំណាយពិតប្រាកដនៅពេលទិញ បូកបន្ថែមចំណាយបន្តបន្ទាប់ដទៃទៀតក្នុងការកែលម្អឱ្យប្រសើរ និងដកចេញថ្លៃផ្នែកខ្លះនៃអចលនទ្រព្យនោះ ដែលបានលក់ចេញឬឈប់ប្រើ ។ មិនអនុញ្ញាតឱ្យធ្វើការកែប្រែតម្លៃដើមអចលនទ្រព្យដែលបានកំណត់តាមមូលដ្ឋាននេះដោយសារតែអតិផរណា ការអភិវឌ្ឍន៍បច្ចេកវិទ្យា ការលក់ឬការផ្ទេរអចលនទ្រព្យនេះ ឬអ្វីផ្សេងទៀតឡើយ លើកលែងតែ នៅពេលណាដែលផ្នែកណាមួយនៃអចលនទ្រព្យរបស់អ្នកកាន់អាជ្ញាប័ណ្ណមួយ ត្រូវបានលក់ឬផ្ទេរឱ្យអ្នកកាន់អាជ្ញាប័ណ្ណនោះ មុនពេលអនុក្រឹត្យនេះចូលជាធរមាន តាមតម្លៃមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាជឿជាក់ថានឹងពុំធ្វើឱ្យប៉ះពាល់ខ្លាំងដល់បញ្ជីថ្លៃលក់របស់អ្នកកាន់អាជ្ញាប័ណ្ណ ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចយល់ព្រមលើតម្លៃដែលផ្ទេរអចលនទ្រព្យនោះបាន ប្រសិនបើការវាយតម្លៃអចលនទ្រព្យនេះត្រូវបានឯកភាពដោយសវនករឯករាជរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

នៅពេលដែលគោលការណ៍ខាងលើពុំអាចកំណត់តម្លៃដើមនៃអចលនទ្រព្យណាមួយបានសមស្រប អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យធ្វើការកំណត់តម្លៃដើមនៃអចលនទ្រព្យនោះ លើមូលដ្ឋាននៃតម្លៃទីផ្សាររបស់អចលនទ្រព្យនោះ ។

២- ក្នុងការកំណត់តម្លៃដើមសរុបនៃអចលនទ្រព្យណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវគិតគូរដល់វិភាគទានណាមួយរបស់អ្នកប្រើប្រាស់ ឬអំណោយដទៃផ្សេងទៀតពីភាគីខាងក្រៅទាក់ទងនឹងអចលនទ្រព្យនោះ ។ អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវកែសម្រួលតម្លៃដើមនៃអចលនទ្រព្យនានា ដើម្បីធានាថាតម្លៃនេះមិនមានបញ្ចូលនូវវិភាគទាន ឬអំណោយខាងលើឡើយ លើកលែងតែអាជ្ញាធរជឿជាក់ថាមានតែវិធីផ្សេងទៀតប៉ុណ្ណោះ ដែលសមស្របជាមួយកាលៈទេសៈពិសេសនៅក្នុងផលប្រយោជន៍សាធារណៈ ។

៣- តម្លៃអចលនទ្រព្យដែលកំពុងឋិតក្នុងការសាងសង់ មិនអនុញ្ញាតឱ្យបញ្ចូលក្នុងតម្លៃដើមរួមនៃអចលនទ្រព្យឡើយ ។ នៅពេលដែលអចលនទ្រព្យនោះដាក់ឱ្យប្រើប្រាស់បានទាំងស្រុងហើយ ទើបតម្លៃអចលនទ្រព្យនោះត្រូវបូកបញ្ចូលក្នុងតម្លៃដើមរួមនៃអចលនទ្រព្យ ។

នៅពេលដែលអចលនទ្រព្យកំពុងឋិតនៅក្នុងការសាងសង់ អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណបូកបន្ថែមពីលើតម្លៃសាងសង់ នូវចំណាយសម្រាប់ការប្រាក់ដែលបានចាយក្នុងអំឡុងពេលសាងសង់ ។ ចំណាយសម្រាប់ការប្រាក់ក្នុងអំឡុងពេលសាងសង់នេះ ត្រូវគណនាសមាមាត្រទៅតាមចំណាយលើការ

សាងសង់ តាមមូលដ្ឋាននៃការបញ្ចូលថ្លៃប្រចាំឆ្នាំ ដោយប្រើប្រាស់អត្រាមធ្យមនៃថ្លៃប្រើប្រាស់ឥណទាន ដែលអ្នកកាន់អាជ្ញាប័ណ្ណបានខ្ចីក្នុងឆ្នាំនោះ ។

នៅពេលដែលអចលនទ្រព្យនោះដាក់ឱ្យប្រើប្រាស់បានទាំងស្រុង ចំនួនទុនដែលត្រូវកំណត់ថាជាតម្លៃអចលនទ្រព្យនោះ គឺជាតម្លៃសរុបលើការសាងសង់ បូកបន្ថែមការប្រាក់ដែលបូករយោងរហូតដល់ថ្ងៃដាក់ឱ្យប្រើប្រាស់អចលនទ្រព្យនោះ ។

៤- នៅពេលណាដែលមានការស្នើសុំពីអ្នកកាន់អាជ្ញាប័ណ្ណឱ្យកំណត់ទុនចល័ត អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់តម្លៃមួយសមស្របសម្រាប់ទុនចល័ត ដែលចាំបាច់សម្រាប់ដំណើរការអាជីវកម្ម ។ ការកំណត់តម្លៃទុនចល័តនេះត្រូវគិតគូរដល់ការទូទាត់ថ្លៃអគ្គិសនីយឺតសមស្របមួយ ដែលអាចកើតមាននៅក្នុងអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណដំណើរការអាជីវកម្មរបស់ខ្លួនជាធម្មតាតាមបទពិសោធន៍ល្អរបស់សហគ្រាសអគ្គិសនី ។

អាជ្ញាធរអគ្គិសនីកម្ពុជាមិនត្រូវកំណត់ឬយល់ព្រមលើការវាយតម្លៃទ្រព្យសកម្មណាមួយខុសពីការកំណត់ក្នុងមាត្រានេះឡើយ ទោះជាទ្រព្យសកម្មរូបិយវត្ថុ ឬអរូបិយវត្ថុ ។

## មាត្រា ១៥.-

ចំពោះចំណាយដទៃផ្សេងទៀត ដែលពុំមានកំណត់ក្នុងអនុក្រឹត្យនេះ អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការរំលោះ តែក្នុងល័ក្ខខ័ណ្ឌដែលអាជ្ញាធរអគ្គិសនីកម្ពុជាជឿជាក់ថា អាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណស្ថិតនៅក្នុងស្ថានភាពមិនប្រក្រតី ប្រសិនបើអាជ្ញាធរអគ្គិសនីកម្ពុជាមិនអនុញ្ញាតឱ្យរំលោះចំណាយទាំងនោះទេ ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណអាចនឹងមានការប៉ះពាល់ធ្ងន់ធ្ងរ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

## មាត្រា ១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ០១ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១៧
- ឯកសារ កាលប្បវត្តិ